ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល លេខ: ១៧៨
ថ្ងៃ: អង្គារ ទី ១១ ខែតុលា ឆ្នាំ២០២១
ម៉ោង: ១៦:០០

# ព្រះរាជក្រម

នស/រកម/១០២១/០១១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា១២៣ មាត្រា១៣៨ មាត្រា១៦២ មាត្រា៣០០ មាត្រា៣៤៣ មាត្រា៣៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ នៃច្បាប់ស្តីពីការងារ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ នាសម័យប្រជុំពេញអង្គលើកទី៧ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
ព្រះរាជដំណាក់
LE MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្តីពី

## វិសោធនកម្មមាត្រា១២៣ មាត្រា១៣៨ មាត្រា១៦២ មាត្រា៣០០ មាត្រា៣៤៣ មាត្រា៣៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ នៃច្បាប់ស្តីពីការងារ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រាមួយ .-**

មាត្រា១២៣ មាត្រា១៣៨ មាត្រា១៦២ មាត្រា៣០០ មាត្រា៣៤៣ មាត្រា៣៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ នៃច្បាប់ស្តីពីការងារ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

**មាត្រា១២៣ .- ថ្មី**

ឥណទេយ្យឯកសិទ្ធិដែលមានចែងក្នុងមាត្រា១២២ថ្មីនៃច្បាប់ស្តីពីការងារ ត្រូវជំទាស់បានលើឯកសិទ្ធិទូទៅនិងឯកសិទ្ធិពិសេស ដោយគិតទាំងឯកសិទ្ធិនៃរតនាគារសាធារណៈផង។ ចំនួនប្រាក់ដែលរតនាគារសាធារណៈបានកាត់លើអាណត្តិរបស់និយោជក នៅក្រោយកាលបរិច្ឆេទបញ្ឈប់ការសងបំណុល ត្រូវប្រគល់ឱ្យទៅកូនបំណុលវិញទាំងអស់។

**មាត្រា១៣៨ .- ថ្មី**

របៀបចែកពេលធ្វើការ ត្រូវកម្រិតដោយសហគ្រាសនីមួយៗ សម្រាប់កន្លែងធ្វើការផ្សេងៗតាមប្រភេទនៃសកម្មភាពនិងរបៀបរៀបចំរបស់ខ្លួន ដោយអាចដំណើរការលើសពី១(មួយ)វេន ក្នុង១(មួយ)ថ្ងៃ។ ក្នុងករណីសហគ្រាសដំណើរការ៣(បី)វេន អាចចែកជាវេនព្រឹក វេនរសៀល និងវេនយប់ ដោយម៉ោងធ្វើការនៃវេននីមួយៗ មិនត្រូវឱ្យលើសថិរវេលាធ្វើការពេញលេញនៃកម្មករនិយោជិតក្នុង១(មួយ)ថ្ងៃ ដូចមានចែងក្នុងមាត្រា១៣៧នៃច្បាប់ស្តីពីការងារ។

សហគ្រាសអាចចែកពេលធ្វើការនៃវេននីមួយៗជា២(ពីរ)វគ្គដាច់ៗពីគ្នា។

**មាត្រា១៦២ .- ថ្មី**

ការធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការការងារ។ បែបបទនិងនីតិវិធីនៃការធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។

ការឈប់សម្រាកថ្ងៃបុណ្យ មិនមែនជាហេតុនាំឱ្យបន្ថយប្រាក់ឈ្នួលប្រចាំខែ ប្រចាំអឌ្ឍមាស ឬប្រចាំសប្តាហ៍ឡើយ។

**មាត្រា៣០០ .- ថ្មី**

វិវាទបុគ្គល គឺជាវិវាទដែលកើតមានឡើងរវាងនិយោជកនិងកម្មករនិយោជិតម្នាក់ឬច្រើននាក់ ឬអ្នករៀនធ្វើការម្នាក់ឬច្រើននាក់ តាមរឿងរៀងៗខ្លួន ហើយទាក់ទងនឹងការបកស្រាយឬការអនុវត្តបទប្បញ្ញត្តិនៃកិច្ចសន្យាការងារ ឬកិច្ចសន្យាហ្វឹកហ្វឺនកម្មករនិយោជិត ឬបទប្បញ្ញត្តិការងារនៃអនុសញ្ញារួម ព្រមទាំងច្បាប់បញ្ញត្តិជាធរមានផង។

ក្នុងរឿងវិវាទបុគ្គល ភាគីណាមួយអាចប្តឹងទៅអធិការការងារដែលមានសមត្ថកិច្ច ដើម្បីធ្វើការផ្សះផ្សាមុនសិន។ ក្នុងករណីមិនសះជា សាមីភាគីអាចប្តឹងទៅតុលាការការងារ ឬក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្របតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា៣៤៣ ._ ថ្មី**

ភារកិច្ចនៃអធិការកិច្ចការងារ ត្រូវប្រគល់ឱ្យទៅអធិការការងារនិងអភិបាលការងារ។

មុននឹងចូលកាន់តំណែង អធិការការងារនិងអភិបាលការងារ ត្រូវស្បថថានឹងបំពេញភារកិច្ចរបស់ខ្លួនដោយល្អ ដោយស្វាមីភក្តិ និងមិនប្រាប់ឱ្យគេដឹងនូវអាថ៌កំបាំងផលិតកម្ម ពាណិជ្ជកម្ម ឬរបៀបធ្វើអាជីវកម្មដែលខ្លួនបានដឹងឮក្នុងពេលបំពេញមុខការខ្លួន ទោះបីខ្លួនចេញពីក្រសួងទទួលបន្ទុកវិស័យការងារហើយក្តី។

អធិការការងារ ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដូចមានចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ចំពោះអធិការការងារ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។

**មាត្រា៣៥០ ._ ថ្មី**

ក្នុងក្របខ័ណ្ឌនៃបេសកកម្មរបស់ខ្លួន បទប្បញ្ញត្តិនានាដែលទាក់ទងដល់សិទ្ធិអំណាចនិងកាតព្វកិច្ចរបស់អធិការការងារកំណត់ក្នុងមាត្រា៣៤៣ថ្មី កថាខណ្ឌទី២ មាត្រា៣៤៦ និងមាត្រា៣៤៧ ចំណុចទី១, ២, ៣, ៤ នៃច្បាប់ស្តីពីការងារ ក៏ត្រូវប្រគល់ជូនអធិការពេទ្យការងារដែរ។

**មាត្រា៣៦៣ ._ ថ្មី**

អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃមាត្រា២១ មាត្រា២៨ មាត្រា៤៤ មាត្រា៤៥ មាត្រា៤៩ មាត្រា៥០ មាត្រា៥៧ មាត្រា៥៩ មាត្រា១០៦ មាត្រា១៣៩ថ្មី មាត្រា១៤៤ថ្មី មាត្រា១៦២ថ្មី មាត្រា១៦៣ មាត្រា១៦៤ មាត្រា១៦៦ មាត្រា១៦៧ មាត្រា១៦៨ មាត្រា១៦៩ មាត្រា១៧០ មាត្រា១៧៩ មាត្រា១៨០ កថាខណ្ឌទី១និងកថាខណ្ឌទី២ មាត្រា១៨២ កថាខណ្ឌទី២និងកថាខណ្ឌទី៣ មាត្រា១៨៤ មាត្រា១៩៤ មាត្រា១៩៨ មាត្រា២០០ មាត្រា២០៤ មាត្រា២០៥ មាត្រា២០៦ មាត្រា២១០ មាត្រា២៤៩ មាត្រា២៥៦ មាត្រា៣០៦នៃច្បាប់ស្តីពីការងារ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ពី៣១(សាមសិបមួយ)ថ្ងៃ ទៅ៦០(ហុកសិប)ថ្ងៃនៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ។

**មាត្រា៣៦៧ ._ ថ្មី**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៣១(សាមសិបមួយ)ថ្ងៃ ទៅ៦០(ហុកសិប)ថ្ងៃ នៃប្រាក់ឈ្នួលយោងចំពោះនិយោជកដែលប្រើប្រាស់បុគ្គលិក ក្នុងលក្ខខណ្ឌផ្ទុយពីបទប្បញ្ញត្តិនៃមាត្រា១៣៧ មាត្រា១៣៨ កថាខណ្ឌទី២ មាត្រា១៤០ និងមាត្រា១៤១ នៃច្បាប់ស្តីពីការងារ។

**មាត្រាពីរ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃអង្គារ ១៤រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ២០២១

[signature]

**នរោត្តម សីហមុនី**

នស/រកម.១០២១.០១៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

[signature]

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

[stamp] [signature]

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

[signature]

**អ៊ិត សំហេង**